**BMI0119**

# សម្ភាសន៍ជាមួយឈ្មោះ ម៉ៅ សារុន ភេទស្រី អាយុ៥៩ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម“កងចល័ត”

## រស់នៅភូមិបន្ទាយឆ្មារខាងលិច ឃុំបន្ទាយឆ្មា ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៤៩:១១

២៦ទំព័រ

វណ្ណៈ: ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង?

សារុនៈ ចាស ។

វណ្ណៈ: ចឹងជាដំបូងដែលខ្ញុំចង់ប្រាប់ថាខ្ញុំមកពីខាងណាដែរ?

សារុនៈ ចាស ។

វណ្ណៈ: ខ្ញុំឈ្មោះសុខ វណ្ណៈ ។

សារុនៈ ចាស ។

វណ្ណៈ: មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានទីតាំងនៅទីក្រុងភ្នំពេញ ។

សារុនៈ ចាស ។

វណ្ណៈ: ចឹងខ្ញុំបានមកដល់ភូមិឃុំរបស់មីងដើម្បីចង់ដឹងរឿងរ៉ាវជាប្រវត្តិសាស្ត្រភូមិនេះដើម្បីចង ក្រងទុកជាឯកសារសម្រាប់ក្មេងជំនាន់ក្រោយ ។

សារុនៈ ចាស ។

វណ្ណៈ: ឲ្យបានដឹងបានពុណាមីងណាស់ ។

សារុនៈ ចាស ។

វណ្ណៈ: ចឹងការសម្ភាសន៍ខ្ញុំជាមួយមីងហ្នឹង ថាតើមីងអនុញ្ញាតឲ្យខ្ញុំយកទៅចងក្រងជាសៀវភៅ បានទេមីង?

សារុនៈ ធ្វើចុះក៏បានទៅមានអី ។

វណ្ណៈ: ចឹងមីងមិនថាអីទេ?

សារុនៈ ចាស!មិនថាអីទេ ។

វណ្ណៈ: ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអីដែរ?

សារុនៈ ម៉ៅ សារុន ។

វណ្ណៈ មីងអាយុប៉ុន្មានហើយ?

សារុនៈ អាយុ៥៩ ។

វណ្ណៈ ប្តីឈ្មោះ?

សារុនៈ ប្តីឈ្មោះ គុល គឿន ។

វណ្ណៈ គាត់អាយុប៉ុន្មានហើយ?

សារុនៈ អាយុ៥៦ ។

វណ្ណៈ ចឹងប្អូនមីងវិញ?

សារុនៈ ចាស!ប្អូនខ្ញុំ

វណ្ណៈ ចឹងមីងសព្វថ្ងៃមានកូនប៉ុន្មាន?

សារុនៈ សព្វថ្ងៃកូន៧នាក់ ។

វណ្ណៈ ស្រីប៉ុន្មាន?

សារុនៈ ស្រី៥ ប្រុសពីរ ។

វណ្ណៈ ចឹងឪពុកបង្កើតមីងឈ្មោះអីដែរ?

សារុនៈ ឪពុកបង្កើតខ្ញុំឈ្មោះ មៅ ដាន់ ។

វណ្ណៈ ម្តាយ?

សារុនៈ ម្តាយឈ្មោះ ដឹម រ៉ែន ។

វណ្ណៈ ចឹងគាត់ទាំងពីរនាក់?

សារុនៈ គាត់ទាំងពីរនាក់គាត់ស្លាប់ដោយសារចាស់ជំងឺ ។

វណ្ណៈ ចឹងស្លាប់ដោយសាចាស់ជំងឺស្លាប់ក្រោយ៧៩?

សារុនៈ ចាសៗ ។

វណ្ណៈ ចឹងបងប្អូនបង្កើតមីងមានប៉ុន្មាននាក់?

សារុនៈ បងប្អូនបង្កើតខ្ញុំមាន៥នាក់ ។

វណ្ណៈ នៅរស់ទាំងអស់?

សារុនៈ ស្លាប់អស់ហើយនៅសល់តែពីរ ។

វណ្ណៈ ចឹងស្លាប់បីនៅជំនាន់ណា?

សារុនៈ ស្លាប់សម័យនេះ៦៥ ។

វណ្ណៈ	ចឹងក្រោយ៧៩ហើយ?

សារុនៈ	ចាស ។

វណ្ណៈ	ចឹងស្រុកកំណើតនៅភូមិ?

សារុនៈ	ស្រុកកំណើតនៅភូមិបន្ទាយឆ្មា ស្រុកបន្ទាយឆ្មា អះស្រុកថ្មពួកតើ ។

វណ្ណៈ	ចង់និយាយកាលពីដើម?

សារុនៈ	កាលពីដើមស្រុក ចាំមើលណាស់ ឃុំបន្ទាយឆ្មា ស្រុកថ្មពួកកាលមុន ឃុំបន្ទាយឆ្មា ។

វណ្ណៈ	ឥឡូវខ្ញុំសួរម្តងទៀត ចឹងភូមិបន្ទាយឆ្មា?

សារុនៈ	ចាស ។

វណ្ណៈ	ឃុំ?

សារុនៈ	ឃុំបន្ទាយឆ្មា ។

វណ្ណៈ	ស្រុក?

សារុនៈ	ថ្មពួក ។

វណ្ណៈ	កាលពីសង្គមចាស់?

សារុនៈ	ចាស!កាលពីសង្គមចាស់មានតែថ្មពួកហ្នឹងឯង ។

វណ្ណៈ	ខេត្តបាត់ដំបង?

សារុនៈ	ចាស!ខេត្តបាត់ដំបង ។

វណ្ណៈ	ចឹងឥឡូវនៅភូមិអីគេ?

សារុនៈ	ភូមិបន្ទាយឆ្មាខាងលិច ។

វណ្ណៈ	ឃុំ?

សារុនៈ	ឃុំបន្ទាយឆ្មា ។

វណ្ណៈ	ស្រុក?

សារុនៈ	ថ្មពួក ។

វណ្ណៈ	ខេត្ត?

សារុនៈ	ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ	ចឹងខេត្តហ្នឹងមីងមានដឹងទេ គេបំបែកតាំងពីឆ្នាំណាមក?

សារុនៈ	ខេត្តហ្នឹងគេបំបែកមិនដឹងថាឆ្នាំប៉ុន្មានពាន់ៗ ខ្ញុំមិនដែលបានចាំណាស់ ។

វណ្ណៈ	ចឹងកាលពូតូចមីងមានបានរៀនសូត្រទេ?

សារុនៈ ចាស! រៀនតើ ។

វណ្ណៈ រៀនបានថ្នាក់ទីប៉ុន្មាន?

សារុនៈ រៀនពីសង្គមមិញនោះខ្ញុំរៀនបានថ្នាក់ទី៩ ។

វណ្ណៈ ទី៩ចាស់?

សារុនៈ ចាស ។

វណ្ណៈ នៅសាលាណា?

សារុនៈ នៅសាលាបឋមសិក្សាបន្ទាយឆ្មាខាងជើង ។

វណ្ណៈ ហេតុអីបានមីងឈប់រៀន?

សារុនៈ ខ្ញុំចុះបើវាធំហើយ ខ្ញុំធំហើយខ្ញុំឈប់រៀន ។

វណ្ណៈ ចឹងនៅពេលឈប់រៀនជួយធ្វើការឪពុកម្ដាយ?

សារុនៈ ចាស! ជួយធ្វើការឪពុកម្ដាយ ។

វណ្ណៈ ចឹងមីងរៀបការនៅឆ្នាំណា?

សារុនៈ ខ្ញុំរៀនការសម័យឆ្នាំ៧៨ សម័យប៉ុល ពតហ្នឹងហើយចាប់ដៃគ្នានោះ ។

វណ្ណៈ ៧៥ បានខ្មែរក្រហមឈ្នះ?

សារុនៈ ៧៨ជិតខ្មែរក្រហមឈ្នះមែន តែចុងឆ្នាំ៧៨ណាស់ ។

វណ្ណៈ ចឹងនៅនេះខ្មែរក្រហមចូលកាន់កាប់មុនហើយ?

សារុនៈ ចាស! ចុងឆ្នាំ៧៨ ។

វណ្ណៈ ចឹងការហ្នឹងមានលោកមានអីទេ?

សារុនៈ អត់ ថាចាប់ដៃគ្នាណាអូន ចាប់ដៃគ្នាប្ដេជ្ញា ។

វណ្ណៈ ចាប់ដៃគ្នាប៉ុន្មានគូរ?

សារុនៈ ចាប់ដៃគ្នា៧៩គូរ ។

វណ្ណៈ ចឹងនៅហ្នឹងខ្មែរក្រហមកាន់កាប់តាំងពីឆ្នាំ៧០ ជាងមក?

សារុនៈ ចាស ។

វណ្ណៈ ចឹងកាលថ្ងៃទី១៧មេសាឆ្នាំ៧៥ហ្នឹង មីងមានបានដឹងថារំដោះបានទាំងស្រុងមែនទេ?

សារុនៈ ចាស ។

វណ្ណៈ ចឹងនៅនេះខ្មែរក្រហមកាន់កាប់មុន?

សារុនៈ	កាន់កាប់មុនតែ តែដល់ថាឆ្នាំ៧៥ វាកាន់កាប់វាចូលមករំដោះបានទាំងស្រុងវាចូលមកណា ។

វណ្ណៈ	បាទ! តែមីងរៀបការមុនហ្នឹងទៀត?

សារុនៈ	ចាស ។

វណ្ណៈ	ចឹងនៅហ្នឹងមានបាយរួមពេលណាហ្នឹង?

សារុនៈ	បាយរួមពេលឆ្នាំ៧៧ ៧៧ វាដាក់រួមហើយ ។

វណ្ណៈ	ហ៊ាក?

សារុនៈ	យី! ឈប់សិន មើល៧៤-៧៥ កាលហ្នឹង៧៦ បាយរួមហើយ ព្រោះខ្ញុំបានកូនខ្ញុំពីបង នោះមួយឆ្នាំកន្លះហើយនោះ មានកូនមួយហើយ ។

វណ្ណៈ	កាលហ្នឹងនៅហ្នឹងគេហៅតំបន់អីទៅ?

សារុនៈ	ហៅតំបន់៥ ។

វណ្ណៈ	ចឹងមានស្គាល់ប្រធានតំបន់ទេ?

សារុនៈ	ប្រធានតំបន់ពួកខ្មែរក្រហម ។

វណ្ណៈ	បាទ ។

សារុនៈ	តា ញិបតែខ្ញុំមិនស្គាល់ត្រកូលគាត់ទេ ។

វណ្ណៈ	តា ញឹម?

សារុនៈ	តា ញិប ៗ គ្នាគាត់មានបីនាក់ តា ញិប តា តឹក តា យីដែលក្តាប់ក្នុងចង្កោមគេណាស់ ។

វណ្ណៈ	ចឹងតា តឹក?

សារុនៈ	តា តឹក តា ញិប តា យី ។

វណ្ណៈ	ចឹងប្រធានភូមិភាគស្គាល់ទេ?

សារុនៈ	ខ្ញុំមិនបានស្គាល់ទេ ប្រធានភូមិភាគ ។

វណ្ណៈ	ចឹងស្គាល់តែប្រធានតំបន់ទេ តា ញិប តា តឹក តា យី?

សារុនៈ	ចាស ។

វណ្ណៈ	ចឹងដល់ក្រោយមកមានការផ្លាស់ប្តូរទៀតទេ?

សារុនៈ	ដល់ក្រោយមកទៀតផ្លាស់ប្តូរ ដល់ចាប់តា ពីរបីនាក់នេះទៅហើយពួកនិរតីចុះមក ។

វណ្ណៈ	ចឹងខាងនិរតីចុះមកឆ្នាំណា?

សារុនៈ មើលខាន់និរតីចុះមកឆ្នាំណាចេះ មើលកូនខ្ញុំបានបីឆ្នាំហើយនោះ កូនខ្ញុំ៧៥នោះ ៧៧ ហ្នឹងឯងមិនមែន៧៨ទេ គេចុះមកឆ្នាំ៧៧ ។

វណ្ណៈ ចុះមកក្រោយហ្នឹងឈ្មោះអីទៅ?

សារុនៈ ឈ្មោះ តា សាំ អា ម៉ាក់ អា ម៉ៃបីនាក់ ហ្នឹងហើយពួកអាក្រោយហ្នឹង ។

វណ្ណៈ ឈ្មោះ ម៉ាក់?

សារុនៈ ចាស! អា ម៉ាក់ អា ម៉ៃ ។

វណ្ណៈ ចឹងម៉ាក់ ម៉ៃហ្នឹងមកធ្វើអី មកកាន់តំបន់ហ្នឹង?

សារុនៈ ចាស!មកកាន់តំបន់ហ្នឹងឯង ។

វណ្ណៈ ចឹងនៅហ្នឹងមានគុកសន្តិសុខមានអីទេ?

សារុនៈ អត់មានទេ មានតែថ្នពួកនេះឯង ។

វណ្ណៈ មានប្រធានសន្តិសុខប្រធានឈ្លបទេ?

សារុនៈ មានហ្នឹងឯង តា នោះឯងដែលខ្ញុំថាហ្នឹង តា ជួបហ្នឹងគាត់ធ្វើប្រធានឈ្លប ។

វណ្ណៈ ចឹងគាត់មិនសួរកាចបានគាត់នៅបាន?

សារុនៈ គាត់មិនកាចទេ គេឲ្យគាត់សម្លាប់គេ គាត់មិនហ៊ាន មានអាអ្នកផ្សេងៗគាត់មិនអីទេ តា នេះនោះ គាត់មិនកាចទេ គាត់ច្រើនជួយមនុស្សរស់បានច្រើនដែលតានេះហ្នឹង ។

វណ្ណៈ ចឹងក្រៅពីគាត់ដូចជាអ្នកដែលអីអត់មានហ៊ានរស់នៅក្នុងភូមិនេះទេ?

សារុនៈ ចាស!មិនហ៊ានទៅទេ ។

វណ្ណៈ ចឹងប្រជាជនដឹងដែរ អ្នកដែលសម្លាប់គេ ហើយអ្នកមិនសម្លាប់គេដឹងទៀត?

សារុនៈ ចុះវាច្រើនហើយបើអាអ្នករត់មិននៅភូមិមិននៅស្រុកនោះ វាមិនហ៊ាននៅ ។

វណ្ណៈ ចឹងពួកភ្នំពេញមានមកដល់នេះទេ?

សារុនៈ ពួកភ្នំពេញមកនេះច្រើនណាស់អាអូនអើយ រាប់រយរាប់ពាន់នាក់ ច្រើនណាស់ ។

វណ្ណៈ ចឹងខ្ញុំចង់ឲ្យមីងរៀបរាប់ត្រួសៗដូចថាមីងឈប់រៀនហើយ កាលសម័យខ្មែរក្រហមមីងធ្វើការនៅកន្លែងណា ហើយបានជួបហេតុការណ៍អីខ្លះ សូមមីងនិយាយមើល?

សារុនៈ ចាស!ចាំមើលខ្ញុំនិយាយ ដល់ពេលខ្ញុំឈប់រៀនហើយខ្ញុំគេដាក់កងចល័តឲ្យខ្ញុំដើរចល័តណាស់ ។

វណ្ណៈ បាទ!និយាយចុះមិនអីទេ ។

សារុនៈ ឲ្យខ្ញុំដើរចល័តហើយឲ្យខ្ញុំលើកប្រពន្ធភ្លឺស្រែ ឲ្យខ្ញុំប្រព័ន្ធភ្លឺស្រែរាប់ពាន់ហិចតា ខ្ញុំដើរកង ចល័តប្រព័ន្ធភ្លឺស្រែ ជីកប្រឡាយជីកអណ្ដូង គេឲ្យទប់ទំនប់ ។

វណ្ណៈ បាទ ។

សារុនៈ ហើយមកដល់រួចហើយ ទៅម្ដងនេះវាចល័តឲ្យយើងដើរកាត់ពាសណាពាសណីណាអាអូន តាំងពីថ្មពួកតាំងពីភ្នំស្រុកដូវំងថ្មបេះតែដើរទៅណាស់ ។

វណ្ណៈ បាទ ។

សារុនៈ ចល័តប្រូតដល់ហើយកូនខ្ញុំវាធំអាយុបីឆ្នាំបួនឆ្នាំ បានអាយុបួនឆ្នាំគេឲ្យខ្ញុំទៅវៃខ្មាំងក្នុងព្រៃ នាំគ្នាលើកកងចល័តទៅវៃខ្មាំងក្នុងព្រៃ ។

វណ្ណៈ មានកាំភ្លើងដែរ?

សារុនៈ មានខ្មាំងមកពីណា មានដំបងកាំបិត មានអីវាយកយើងទៅវៃចោល តែវាមិនជួបគ្នាវា វាឲ្យយើងមកវិញមក ។

វណ្ណៈ ចឹង?

សារុនៈ ចាស!វាយកយើងទៅវៃចោល ពួកខ្ញុំដឹងទៅប្រឹងស្មារតីទាំងអស់គ្នាទៅរាប់ពាន់នាក់នោះ វាដែលហ៊ានណា ហើយពួកខ្ញុំក៏មកវិញមក ពីរបីសារពីរបីលើកផ្ញើតែបេះឯង ។

វណ្ណៈ បាទ ។

សារុនៈ ចង់ងាប់ចង់រស់ហើយទៅប្រូតទៅស្ទូងពីម៉ោង៤ រហូតដល់ម៉ោង១២ស្ទូងបានមកជួបកូន វិញ សំណាំងហើយកូនតែមួយបើសិនជាកូនពីរបីស្លាប់មុនកូនហើយខ្ញុំ កូននោះក៏អាយុ វែងទៀត៤០នាក់ងាប់អស់រលីងនៅសល់តែកូនខ្ញុំមួយ ។

វណ្ណៈ កូន៤០នាក់យ៉ាងម៉េច?

សារុនៈ មនុស្សម៉ែៗទាំងអស់ហ្នឹងមានកូនក្មេង៤០នាក់ទុកឲ្យយាយៗមើលនៅខ្ទមឯនេះណាអា អូនហើយយើងទៅស្ទូងទៅដកណាស់ ។

វណ្ណៈ បាទ ។

សារុនៈ កាលហ្នឹង៤០នាក់បានរស់តែកូនខ្ញុំមួយប៉ុណ្ណោះឯងនៅសព្វថ្ងៃ ។

វណ្ណៈ ចឹងប្រមូលក្មេង?

សារុនៈ ចុះប្រមូលវាឈឺនោះអាអូន មុនមានពីណាមើលមានតែយាយម្នាក់ហ្នឹង គាត់មើលម៉េច គ្រាន់ បើម៉ែមួយកូនមួយមើលមិនចង់គ្រាន់ផង ។

វណ្ណៈ បាទ ។

សារុនៈ ទំរាំកូន៤០ឲ្យយាយមើលម្នាក់ឯងមើលម៉េចគ្រាន់ ឈឺស្លាប់អស់ទៅនៅសល់តែកូនខ្ញុំមួយ ។

វណ្ណៈ ចឹងប្រមូលយកឲ្យតែយាយម្នាក់មើលទេ?

សារុនៈ ចាស!ដែលមានមនុស្សច្រើនកូនង៉ា ។

វណ្ណៈ ក្មេងប៉ុនណាៗ?

សារុនៈ កូនង៉ែតក៏មានអាកូនចេះអង្គុយក៏មាន ចេះដើរក៏មាន ។

វណ្ណៈ ពីមួយខួបពីមួឆ្នាំឡើង?

សារុនៈ ពីមួយឆ្នាំចុះក្រោម ដល់បីឆ្នាំហើយគេឈប់ឲ្យយាយមើលហើយ គេដាក់មួយកន្លែងដល់អាយុបីឆ្នាំហើយ ។

វណ្ណៈ ចឹងកាលហ្នឹងចំនួន៤០នាក់?

សារុនៈ ចាស!៤០នាក់រស់បានតែកូនខ្ញុំមួយ កើតឆ្នាំរោង ។

វណ្ណៈ ចឹងដោយសារអីបានជាងាប់បានជាស្លាប់?

សារុនៈ ចុះបើមិនមានម្តាយនៅរក្សាហ្នឹងនោះបានអីមិនស្លាប់ ម៉ោង៤ចេញម៉ោង១២យប់ចូលស្ងួតៗធ្វើការមួយថ្ងៃៗមិនដែលមានពេលសម្រាកហើយមិនដែលមានបាយហូបទៀត ធ្វើស្រែបានមិនដឹងជាយកទៅណា ហូបបបរខូសខស់ពួកខ្ញុំខាងនេះមិនដែលមានបាយហូបទេ ហូបតែមើមឈើមើមព្រៃ ។

វណ្ណៈ ចឹងការហូបចុកក៏លំបាកការងារក៏លំបាក?

សារុនៈ ចាស!ពិបាកទាំងអស់ ។

វណ្ណៈ ចឹងមីងសង្កេតឃើញថា អ្នកភូមិដ្ឋាននិងអ្នក១៧មេសាហ្នឹងមានការហូបចុកខុសគ្នាដែរ?

សារុនៈ ចាស!នៅភូមិខ្ញុំនៅតំបន់ហូបពិបាកទាំងអស់គ្នា ។

វណ្ណៈ ចឹងអ្នក១៧មេសាដែលមករស់នៅក្នុងភូមិនេះ ភាគច្រើនស្លាប់នៅទីនេះឬមួយមានវាសនាបានទៅស្រុកកំណើតគេវិញ?

សារុនៈ មានវាសនាខ្លះស្លាប់នៅខ្លះស្លាប់នៅភូមិនេះ ។

វណ្ណៈ ស្លាប់ច្រើនដាងទៅឬមួយយ៉ាងម៉េច?

សារុនៈ ស្លាប់ច្រើនដាងទៅ ស្លាប់នោះស្លាប់ហើយគដើងគច្រវ៉ាក់គ្នានោះនៅអាងដើងគ្រោះមិនដឹងជាប៉ុន្មានលាននាក់ទេ គ្នាស្លាប់សុទ្ធតែចិន គ្នារែកដីលើកទំនប់មិនរួចចចុះរែកដីឡើងទំនប់មិនរួចចុះចំណាស់ប្រហែលខ្ញុំប្រហែលប្អូនឯងហើយ ចុះគ្នាអត់មានបាយធំតែក្បាល

ជន្លង់គ្នាឡើងមិនរួចវ៉ៃគ្នាថែម សម្លាប់ចោលទម្លាក់ក្នុងអាងច្រើនទម្លាក់ក្នុងទំនប់នោះច្រើន ធ្វើបាបគ្នាប្តីខ្ញុំយំរាល់ថ្ងៃ ប្តីខ្ញុំគេឲ្យធ្វើឈ្លបគេឲ្យធ្វើគិញសម្ងាត់ទេ គេមិនបានឲ្យសម្លាប់អីណាទេ ប្តីខ្ញុំហ្នឹង ឲ្យធ្វើគិញសម្ងាត់ឲ្យគេឃើញពីណាអីគាត់មិនហ៊ានទេ ឲ្យតែប្រធានហ្នឹងឯង ។

វណ្ណៈ: ចឹងអង្គការវ៉ៃចោលទម្លាក់អាង?

សារុនៈ ទម្លាក់ដូចយើងដាក់ទំនប់ ទំនប់មិនទាន់ពេញដីហ្នឹងទម្លាក់ទៅអាក្នុងនោះណាអាអូនខ្នងអាងហ្នឹងវ៉ៃចោលច្រើន មានចាប់តាំងពីកូនក្មេងមានតាំងពី២០ឆ្នាំ១៨ឆ្នាំមានបងប្អូនពីរនាក់ចឹងទៅចាប់ទៅកប់ដីទាំងរស់ក៏មានដែរ ក្នុងអាងដើងគ្រោះនេះណាស់ ។

វណ្ណៈ: ចឹងមឹងពុតាមគេថា?

សារុនៈ ពុហ្នឹងឯងប្តីខ្ញុំគាត់ទៅឈ្លបហ្នឹងឯង ។

វណ្ណៈ: ចឹងប្តីនិយាយប្រាប់?

សារុនៈ ចាស!ប្តីនិយាយប្រាប់ ខ្ញុំមិនបានឃើញទេប្តីខ្ញុំគាត់និយាយ ប្តីខ្ញុំនិយាយថាឯងអើយកុំធ្វើមាត់ធ្វើកខ្លាច គេយកទៅទាំងរស់ៗចេះនោះឯងអើយកុំធ្វើមាត់ខ្ញុំក៏ស្ងៀមតាមប្តីទៅ មិនដែលហ៊ានទេ ។

វណ្ណៈ: ចឹងអ្នក១៧មេសាអង្គការចាប់សម្លាប់ចោលច្រើន?

សារុនៈ ច្រើនរាប់រយរាប់ពាន់នាក់ តាំងពីចិនតាំងពីខ្មែរគេសម្លាប់ចោលអស់ មិនដឹងជាអស់ប៉ុន្មានពាន់នាក់ទេ អ្នកស្រុកនេះ ។

វណ្ណៈ: ចឹងមានអ្នកមូលដ្ឋានចាស់អីមានចាប់វ៉ៃចោលដែរ?

សារុនៈ ចាប់វ៉ៃដែរ ។

វណ្ណៈ: អ្នកមូលដ្ឋានអ្នកស្រុកភូមិហ្នឹងតែម្តងណាស់?

សារុនៈ ចាប់វ៉ៃដែរ ។

វណ្ណៈ: តែមិនច្រើនដូចអ្នក១៧មេសាទេ?

សារុនៈ ចាស!បើវ៉ៃមើលខ្ញុំដាំបាយ ខ្ញុំគេឲ្យធ្វើប្រធានក្រុមដាំបាយ ។

វណ្ណៈ: ដាំបាយសហករណ៍?

សារុនៈ អត់ទេ ដាំបាយក្រុមហើយដាំបាយតាមក្រុមហើយមេប្រធានឃុំហ្នឹងវាមិនចេះអក្សរ ហើយយកក្រដាសមួយសន្លឹកឈ្មោះប្រហែលជា៣៦នាក់ឃើញមានឈ្មោះខ្ញុំទៀត ខ្ញុំបានហែកចោលទៀត ដែលខ្ញុំចេះអក្សរណាស់ ។

វណ្ណៈ	បាទ ។

សារុនៈ	សំណាងហើយដែលឈ្មោះខ្ញុំនៅក្រោមគេចេះឯង ។

វណ្ណៈ	ឈ្មោះហ្នឹងគេយកទៅណា?

សារុនៈ	ឈ្មោះហ្នឹងគេយកទៅវ៉ៃចោល ។

វណ្ណៈ	ម៉េចបានមីងដឹងថាយកទៅវ៉ៃចោល?

សារុនៈ	ម៉េចបានដឹងបើគេឲ្យខ្ញុំគេប្រាប់ខ្ញុំឲ្យលឿនៗល្ងាចឡើងឃើញយកខោអាវមកវិញហើយគោរទេះមកវិញដដែល ។

វណ្ណៈ	បាទ ។

សារុនៈ	ហើយម្នាក់នោះរត់ទៅនៅបារាំង គេវ៉ៃប្រពន្ធកូនវាចោលអស់មនុស្សរាប់ពាន់នាក់នៅសល់តែវាមួយវារត់ទាំងចំណងអាអូន ។

វណ្ណៈ	បាទ ។

សារុនៈ	វានៅសព្វថ្ងៃឈ្មោះ អា ដាង ប៉ុន្មានឆ្នាំនេះគេមកយកបងប្អូនគេ ។

វណ្ណៈ	គេយកទៅវ៉ៃចោលដែលតែរត់រួច?

សារុនៈ	ចាស!មិនទាន់វ៉ៃដល់គាត់ទេ តែគាត់រត់ទាំងចំណងទៅហ្នឹង រត់ទាំងខ្សែទៅហ្នឹងគេចងដៃគាត់ហ្នឹង ។

វណ្ណៈ	បាទ ។

សារុនៈ	រត់ទាំងខ្សែហើយប្រពន្ធកូនបងប្អូនទាំងអស់គ្នាហ្នឹងគេវ៉ៃងាប់អស់ នៅសល់តែគាត់មួយកន្ទុយក្រោយគេហ្នឹង គេកាត់ខ្សែជិតយកគាត់ទៅហើយគាត់រត់បាញ់គាត់មិនត្រូវ បាញ់គាត់មិនត្រូវសព្វថ្ងៃគាត់នៅតើ រត់រួចតែគាត់មួយប្រពន្ធកូនបងប្អូនគាត់បងប្អូនប៉ុន្មានពាន់នាក់គេសម្លាប់ចោលអស់ហើយ គាត់រតទៅផុតហើយប៉ុន្មានឆ្នាំនេះគាត់មកយកបងប្អូនគាត់ ។

វណ្ណៈ	ឈ្មោះអីដែលគេយកវ៉ៃចោលរត់រួច?

សារុនៈ	រកនឹកសិនឈ្មោះ តាប់ ដាង ឈ្មោះកំណើតគាត់ដាងចេះឯង តាប់ហៅដាង ។

វណ្ណៈ	បាទ ។

សារុនៈ	គាត់រត់រួចគាត់បានទៅនៅអីបារាំង គាត់មកយកប្អូនគាត់បងគាត់ទៅនៅអស់ហើយសព្វថ្ងៃហ្នឹង ។

វណ្ណៈ	ចឹងសព្វថ្ងៃគាត់នៅណា?

សារុនៈ នៅបារាំង ។

វណ្ណៈ គាត់ធ្លាប់មកលេងហ្នឹងបានប៉ុន្មានដង?

សារុនៈ មកបីដងគាត់មកយកបងប្អូនគាត់ ។

វណ្ណៈ ចឹងមីងកាលប្តីមីងបានធ្វើឈ្លបដែលប្តីមីងប្រាប់ថាអង្គការសម្លាប់មនុស្សអីមីងដឹងដែរ?

សារុនៈ ដឹងប្តីខ្ញុំគាត់និយាយ ។

វណ្ណៈ ចឹងមីងមានដឹងថា ពេលយកអ្នក១៧មេសាសម្លាប់ហ្នឹងមីងមានដឹងថាមានបញ្ជាពីថ្នាក់ស្រុក ថ្នាក់ខេត្តមកឬមួយយ៉ាងម៉េច?

សារុនៈ មានបញ្ជាពីថ្នាក់ស្រុកថ្នាក់ខេត្តហ្នឹងឯង ប្តីខ្ញុំគាត់និយាយប្តីខ្ញុំគាត់ប្រាប់ខ្ញុំ ។

វណ្ណៈ ចឹងមានឈ្មោះមកពីខាងលើ?

សារុនៈ ចាស!ឈ្មោះមកពីលើ ឈ្មោះគេយកមកពីលើគេឲ្យមក ។

វណ្ណៈ ចឹងមានឈ្មោះមកពីគណៈតំបន់ដែរ?

សារុនៈ ចាស!មកពីគណៈតំបន់ហ្នឹងឯងបានដល់មកនេះហ្នឹង ។

វណ្ណៈ ចឹងមិនមែនមេភូមិមេឃុំនេះសម្លាប់ខ្លួនឯងទេ?

សារុនៈ អត់ទេ អត់មានទេ ។

វណ្ណៈ ចឹងមិនមែនមានសិទ្ធត្រឹមឈ្លបត្រឹមមេកងអីទេ?

សារុនៈ អត់ទេ ។

វណ្ណៈ ចឹងអត់មានចង់សម្លាប់ប្រជាជនដោយចិត្តខ្លួនឯងទេគឺមកពីថ្នាក់លើ?

សារុនៈ អត់ទេ សុទ្ធតែថ្នាក់លើឲ្យសំបុត្រមកបានខាងនេះហ៊ាន ។

វណ្ណៈ បាទ ។

សារុនៈ នៅនេះអត់មានហ៊ានទេ ។

វណ្ណៈ ចឹងប្តីមីងកាន់កាប់ដល់ពួកនិរតីចូលមកពួកគាត់រត់ទៅថៃឬមួយនៅជាមួយពួកហ្នឹងទៀត?

សារុនៈ ប្តីខ្ញុំគាត់ឈប់ ឈប់ហើយនៅធ្វើការធម្មតាភ្ជួរស្រែភ្ជួរចំការ ។

វណ្ណៈ ចឹងពួកនិរតីវាអត់មានស្រាវជ្រាវរក?

សារុនៈ ចាស!អត់ទេ មកវាចាប់រើសមនុស្សថ្មីទៀត ហើយយកម្តងនេះយកតែកូនក្មេងស្ទាវៗ យកតែកូនក្មេងតូចៗយកត្រឹមអាយុ១៣-១៨ឆ្នាំអាស្តាយកាំភ្លើងអូសដីហ្នឹងអាអូនវា យកតែអាប៉ុណ្ណោះឯង ។

វណ្ណៈ ចឹងតា ជួប?

សារុនៈ	តា ជួប គាត់ធំហើយ គាត់ចាស់គ្រាន់ហើយ គាត់អាយុប្រហែលជា២០ជាងហើយគាត់ធ្វើនោះ ។

វណ្ណៈ	ចឹងនៅពេលដែលនិរតីចូលមកគាត់ឈប់ដែរ?

សារុនៈ	ចាស ។

វណ្ណៈ	ចឹងគាត់ឈប់ទាំងអស់គ្នា?

សារុនៈ	ចាស ។

វណ្ណៈ	ចឹងខាងពួកនិរតីមកអត់មានស្រាវជ្រាវចាប់ប្រធានឃុំប្រធានឈ្លបអីទេ?

សារុនៈ	ចាប់តើ ។

វណ្ណៈ	ចឹងតា ជួបម៉េចគេមិនចាប់?

សារុនៈ	តា ជួបគេមិនចាប់គាត់ទេ ព្រោះមិនមានឈ្មោះគាត់នោះ គាត់ដូរឈ្មោះឲ្យគេនោះ គាត់ដូរឈ្មោះឲ្យគេ ។

វណ្ណៈ	ចឹងគាត់ដូរឈ្មោះ?

សារុនៈ	ចាស ។

វណ្ណៈ	ចឹងដូចគាត់ធ្លាប់ធ្វើចឹងគាត់ដាក់ឈ្មោះផ្សេងទៅ?

សារុនៈ	ចាស ។

វណ្ណៈ	ចឹងគេចាប់អ្នកផ្សេងទៅ?

សារុនៈ	ចាស!កុំអីគាត់ដដែល ។

វណ្ណៈ	កុំអីគេចាប់គាត់ដែរ?

សារុនៈ	ចាស ។

វណ្ណៈ	ចឹងពួកនិរតីចូលមកហ្នឹងអ៊ីៗត្រូវផ្លាស់ប្តូទាំងអស់?

សារុនៈ	ចាស!ផ្លាស់ទាំងអស់ ។

វណ្ណៈ	ចឹងប្រព័ន្ធសន្តិសុខនៅទីនេះ?

សារុនៈ	ចាស!ផ្លាស់ទាំងអស់ ។

វណ្ណៈ	ចឹងប្រព័ន្ធសន្តិសុខនៅនេះខាងនិរតីគ្រប់គ្រង ហើយចាប់អ្នកធ្វើឈ្លបចាស់ៗហ្នឹងយកទៅវៃចោល?

សារុនៈ	វៃចោលបើសិនជាដឹង ។

វណ្ណៈ	ចឹងមាននៅកន្លែងខ្លះពួកហ្នឹងមានរត់ទៅថៃ?

សារុន៖ ចាស!រត់ទៅថៃខ្លះទៅនាំគ្នារត់ទៅខ្លះស្លាប់ទៅដូចជាបងខ្ញុំរត់ទៅស្លាប់លើខ្នងភ្នំត្រូវមីន ។

វណ្ណៈ៖ រត់ជំនាន់ណា?

សារុន៖ រត់ជំនាន់ពួកនិរតីមកហ្នឹងឯង ។

វណ្ណៈ៖ ចឹង?

សារុន៖ រត់ទៅគ្នា២០ ប៉ុន្មាននាក់ស្លាប់តែពីរនាក់បងខ្ញុំបង្កើតមួយប្អូនជីដូចមួយមួយអត់មានពីណាសម្លាប់ទេ រត់ទៅស្លាប់ខ្លួនឯងត្រូវមីនជាន់មីន ។

វណ្ណៈ៖ ចឹងជំនាន់ខ្មែរក្រហមហ្នឹងមានអ្នករត់ទៅថៃច្រើនទេ?

សារុន៖ មាន ។

វណ្ណៈ៖ តែមិនសូវមានរស់ទេ?

សារុន៖ ចាស!មិនសូវមានរស់ច្រើនប៉ុន្មានទេ មាន តា ឪហ្នឹងឯងទៅថៃគាត់បានប្រពន្ធនៅថៃសព្វថ្ងៃនេះឯង ។

វណ្ណៈ៖ ឥឡូវគាត់ត្រឡប់មកវិញ?

សារុន៖ ចាស!គាត់ត្រឡប់មកវិញ គាត់មកនៅស្រុកវិញ ។

វណ្ណៈ៖ ចឹងនៅពេលដែលពួកនិរតីចូលមកគាត់រត់ដែរ?

សារុន៖ ចាស ។

វណ្ណៈ៖ ចឹងភាគច្រើនពួកអ្នកធ្វើការជំនាន់ខ្មែរក្រហមហ្នឹងពួកនិរតីមករត់ចេញ?

សារុន៖ ចាស!ប្រុសៗសុទ្ធតែរត់ហើយ ។

វណ្ណៈ៖ ចឹងពេលរត់ទៅហ្នឹងពីហ្នឹងទៅដល់ថៃមានចម្ងាយប៉ុន្មានដែរ?

សារុន៖ ពីនេះទៅថៃឆ្ងាយគ្រាន់ដែរ ។

វណ្ណៈ៖ ឆ្ងាយគ្រាន់?

សារុន៖ ចាស!ឆ្ងាយគ្រាន់មើលយើងទៅផ្សារណាត់ "អ្នកជិតនិយាយសព្វវាផ្សេង" ហ្នឹងថាផ្សេងហើយដូចឡានគោយន្តចុះដូចថាយើងនិយាយផ្សឹង ។

វណ្ណៈ៖ បាទ ។

សារុន៖ ចាស!ថាយើងដើរថាមួយថ្ងៃចុះ ដើរមួយថ្ងៃចុះពីនេះទៅថៃ ពីនេះឆ្លងភ្នំដុតណាស់ ពីនេះទៅអំពិលយើងដើរដល់យើងដើរទៅមិនយប់ផង ទោះបីឆ្លងភ្នំក៏មិនដល់មួយយប់មួយថ្ងៃតែមួយថ្ងៃហ្នឹងឯង ។

វណ្ណៈ៖ ចឹងពេលទៅដល់ថៃមិនខ្លាចថៃចាប់បញ្ជូនមកវិញទេ?

សារុនៈ ថៃវាមានរ៉ៃចោលដែលអូន មានអ្នករត់មកប្រាប់ថាថៃវារ៉ៃចោលខ្លះ វាស្រណោះខ្លះវារ៉ៃចោលខ្លះវាយកទៅខ្លះ ។

វណ្ណៈ ចឹងកាលណាមានលុយឲ្យវា វាឲ្យរួចខ្លួន?

សារុនៈ ចាស!សម័យនោះយើងមិនដឹងជាមានលុយមកពីណាទេ វាអត់តែយើងសំពះគេទាន់ទៅយើងសុំទោសអីគេទៅទាន់ទៅគេស្រណោះគេយកទៅៗ អ្នកដែលមិនបានសុំទោសគេវាសម្លាប់ចោល វាភាគច្រើនណាស់សម្លាប់ចោលពួកថៃមិនមែនធម្មតាទេ គេក៏ធ្វើបាបយើងដែលហ្នឹង ស្លាប់ច្រើនដោយសារឡើងទៅដល់ថៃហើយស្លាប់មិនមានតិចទេរាប់ពាន់នាក់ ។

វណ្ណៈ ចឹងអ្នករត់ទៅថៃមានសំណាងតិចណាស់ ព្រោះជួបខ្មែរក្រហមផងជួបថៃចិត្តអាក្រក់ផង?

សារុនៈ ចាស ។

វណ្ណៈ ចឹងជួនថៃបញ្ជូនមកវិញជួនវាសម្លាប់?

សារុនៈ ចាស!ត្រូវហើយ ។

វណ្ណៈ ចឹងបើថៃបញ្ជូនមកក៏ខ្មែរក្រហមសម្លាប់ដែរ?

សារុនៈ ចាស!ភាគតិចណាស់ដែលបានរស់នៅនោះខ្មែរយើងកម្មវេទនាណាស់ ។

វណ្ណៈ ចឹងនៅពេលស្រុកស្រួលមានអ្នករត់ទៅថៃហើយបានមកលេងស្រុកដែរ?

សារុនៈ ចាស!មកច្រើន ។

វណ្ណៈ មកស្រុកវិញ?

សារុនៈ ចាស!មកស្រុកវិញ ។

វណ្ណៈ ចឹងនៅខាងនេះជំនាន់ខ្មែរក្រហមបើសិនជាយើងមិនរត់ក៏ប្រឈមនិងការស្លាប់ដែរ?

សារុនៈ ចាស!ត្រូវហើយ ។

វណ្ណៈ ចឹងពួក១៧មេសាមានប្រថុយរត់ទេពួកហ្នឹង?

សារុនៈ មានប្រថុយរត់តែរត់មិនផុត ។

វណ្ណៈ ណាមួយមិនសូវដឹងផ្លូវព្រោះមកពីភ្នំពេញ?

សារុនៈ ចាស ។

វណ្ណៈ ចឹងបើចង់រត់មានតែរត់មកជាមួយគេអ្នកមូលដ្ឋាន?

សារុនៈ បានឪពុកខ្ញុំនាំទៅបាន៦គ្រួសារ ។

វណ្ណៈ ចឹង?

សារុនៈ ចាស!គាត់ទៅដល់អាមេរិកគាត់គេមកឪពុកខ្ញុំ ឪពុកខ្ញុំស្លាប់បាត់បាន៦គ្រួសារតែខ្ញុំមិនបានស្គាល់គាត់ទេ ឃើញគាត់ឲ្យលុយពុកខ្ញុំពុកខ្ញុំគាត់មិនយកទេ គាត់អ្នកចាស់បុរាណណាស់ អត់ចង់បានទេ គាត់ថាឲ្យតែបានរស់ទាំងអស់គ្នា គេឲ្យមាសអីឪពុកខ្ញុំមិនយកទេ ។

វណ្ណៈ បាទ ។

សារុនៈ គ្រហាមតែគាត់មិនយក ព្រោះខ្លាចទៅខាងមុខមិនមានអីគាត់មិនយក គេថាមិនអីទេអឹខ្ញុំមាន គេឲ្យកំប៉ុងមាសមើលពុកខ្ញុំថាអត់ទេ ជូនដុតទៅ៦គ្រួសារដែរ ។

វណ្ណៈ បាទ ។

សារុនៈ កាលសម័យនោះពុកខ្ញុំ គាត់លួនជូនទៅ៦ទៅ៧គ្រួសារហ្នឹងមានពីរនាក់មានម្នាក់មានបីនាក់ មានបួននាក់ ។

វណ្ណៈ ចឹងឪពុកមីងធ្វើអីដែលបានមានសិទ្ធជូនទៅ?

សារុនៈ គាត់មិនមានធ្វើអីទេ ។

វណ្ណៈ ចឹងគាត់អត់មានខ្លាចខ្មែរក្រហមដឹងទេ?

សារុនៈ ចុះបើគាត់ចាស់បុរាណគាត់លួចគាត់ធ្លាប់ដឹងផ្លូវហ្នឹងអាអូន គាត់យ៉ាងម៉េចខ្លាចព្រោះគាត់គ្រូ គ្រូខ្មែរ ពុកខ្ញុំជួយយកអាសារបងប្អូនបាន៧ទៅ៨នាក់ហើយ ។

វណ្ណៈ ចឹងមានប៉ុន្មាននាក់ដែលជូនទៅហ្នឹង?

សារុនៈ ៧គ្រួសារ ។

វណ្ណៈ ៧គ្រួសារតែមានគ្នារបហែលជាប៉ុន្មាននាក់?

សារុនៈ ប្រហែលជា១៥នាក់ មានកូនក្មេងចេះដើរហើយមួយគ្រួសារបីមួយគ្រួសារពីរខ្លះទៅ៦ខ្លះម្នាក់ឯងទៅពីរនាំបីនាក់ច្រើន ច្រើនតែពីរនាក់ហ្នឹងឯងក្មេងៗកូនមួយកូនពីអីខ្លះស្លាប់កូនអស់ទៅនាំគ្នារត់ប្រថុយតើ ជួបពុកខ្ញុំពុកខ្ញុំគាត់ស្រណោះ ។

វណ្ណៈ ចឹងក្រោយមកមានបានផ្ញើរលុយឲ្យឪពុកមីងទេ?

សារុនៈ អត់មានបានផ្ញើរទេ ព្រោះពុកខ្ញុំស្លាប់ហើយ ។

វណ្ណៈ ចឹងធ្វើម៉េចបានដឹងថាពួកហ្នឹងបានទៅដល់អាមេរិច?

សារុនៈ ចុះគាត់ប្រាប់មកថាគាត់នៅអាមេរិច ។

វណ្ណៈ ចឹង?

សារុនៈ ចាស!នៅសល់តែកូនខ្ញុំមិនដឹងជានិយាយថាអី ខ្ញុំយំទៅខ្ញុំស្រណោះឪពុកខ្ញុំ គាត់មិនបានផ្ញើរមកទេ បើគា ស្លាប់ហើយខ្ញុំមិនបានផ្ញើទេ គេឃើញសាគុណគាត់តែគេមិនបានឲ្យទេ ។

វណ្ណៈ ចឹងនៅពេលដែលពួកនិរតីចូលមកជីវភាពប្រជាជនកាន់តែតឹងឡើងឬមួយយ៉ាងម៉េចដែរ?

សារុនៈ ចាស!កាន់តែតឹងឡើង អត់មានធូរទេ កាន់តែតឹងឡើងៗ មិនដែលមានស្អីហូបទេ សម្បីតែដាំបន្លែបន្ការខ្លួនឯងក៏មិនហ៊ានបេះហូប សុខចិត្តតែអត់រស់ទាំងវេទនារស់ទាំងទឹកភ្នែក ធ្វើស្រែរាប់ពាន់បាវរាប់ពាន់ថាំងយ៉ាងណាក៏មិនដែលមានស្រូវទុកហូបមិនដាគេយកទៅខាងណាម្ន៉ឹត យើងមានអីហូប ហូបតែបុសឈើឬសព្រៃដំឡូង បើវាឲ្យហូបបបរមួយចានប៉ុននេះមានគ្រាប់អង្ករប្រហែលជាមួយកូនចានឲ្យហូបគ្នា៨នាក់ ។

វណ្ណៈ បាទ ។

សារុនៈ អង្ករមួយចានចង្កឹះប៉ុននេះវាបបរយើងហូបគ្នា៨នាក់ ម្ល៉េះហើយប្រជាជនចេះតែតស៊ូកុំតែឲ្យគេវៃចោល ធ្វើយ៉ាងម៉េចឲ្យតែរស់ ។

វណ្ណៈ ចឹងបើតាមមីងជាអ្នកមានស្រុកកំណើតនៅទីហ្នឹង មីងគិតថាភូមិនេះមានរាប់រយឆ្នាំរាប់ពាន់ឆ្នាំមកហើយឬយ៉ាងម៉េច?

សារុនៈ ចាស!ភូមិនេះមានរាប់រយឆ្នាំមកហើយ ។

វណ្ណៈ ចាស់ៗនិយាយតគ្នា?

សារុនៈ ចាស!ម៉ែខ្ញុំជីដូនខ្ញុំគាត់និយាយថា កើតមករាប់រយឆ្នាំហើយមកចាប់កំណើតនៅភូមិនេះរាប់រយឆ្នាំ ។

វណ្ណៈ ចឹងភាគច្រើនអ្នកស្រុកអ្នកភូមិនេះគេប្រកបមុខរបរអីវិញ?

សារុនៈ ចាស!ភាគច្រើនប្រកបមុខរបរធ្វើតែស្រែចំការហ្នឹងឯង ។

វណ្ណៈ តាំងពីដើមមក?

សារុនៈ ចាស ។

វណ្ណៈ ចឹងប្រាសាទបន្ទាយឆ្មាហ្នឹងមីងកើតមកដឹងថាមានប្រាសាទហ្នឹងតែម្តង?

សារុនៈ កើតមកថ្ងៃនេះឃើញថ្ងៃនេះក៏ថាបាន ខ្ញុំកើតនៅនេះឯងរស់នៅនេះឯង ។

វណ្ណៈ ចឹងជំនាន់ខ្មែរក្រហមមីងមានដែលទៅលេងក្នុងប្រាសាទទេ?

សារុនៈ ចាស!មិនដែលបានចូលទេ គេមិនឲ្យចូលទេកូន ។

វណ្ណៈ មានទាហានយាមទេ?

សារុនៈ ចាស!ពួកខ្មែរក្រហមយាម បើក្មេងចូលធ្វើការក្នុងនោះបាន ពួកខ្ញុំធំៗចេះគេមិនឲ្យចូល ។

វណ្ណៈ ចឹងមីងគិតថាជំនាន់ខ្មែរក្រហមវត្ថុបុរាណនៅក្នុងប្រាសាទមានច្រើនទេ?

សារុនៈ មានតើមានច្រើន ។

វណ្ណៈ តែក្រោយមកបាត់បង់ទេ?

សារុនៈ តែបាត់បង់យួនរំដោះសម័យប៉ុាភហ្នឹងឯង ។

វណ្ណៈ ចឹងសម័យប៉ុាភ?

សារុនៈ ចាស!សម័យប៉ុាភ ។

វណ្ណៈ ចឹងប៉ុាភកើតតាំងពីពេលណាមក?

សារុនៈ ប៉ុាភមិនកើតតាំងពីឆ្នាំប៉ុន្មានទេ ខ្ញុំក៏មិនបានគិតថាឆ្នាំប៉ុន្មានឆ្នាំអីមើល មុនយួនរំដោះដឹងប៉ុន្មានឆ្នាំហើយមុនយួនរំដោះហ្នឹង បើរត់ទៅព្រៃរត់ទៅយូរហើយនេះ ។

វណ្ណៈ ចាំមើលខ្ញុំមិនដឹងថា ខាងប៉ុាភនៅភូមិភាគនេះកើតនៅឆ្នាំណាទេ?

សារុនៈ មី!រដ្ឋកើតនៅឆ្នាំប៉ុន្មាន ។

វណ្ណៈ ចឹងនៅពេលវៀតណាមចូលមកនៅឆ្នាំ៧៩ហ្នឹងប្រជាជនទាំងអស់ហ្នឹង មានរត់ទៅខាងណាទេ ឬមួយមិនបានរត់ទេ?

សារុនៈ ប្រជាជនរត់ទៅខាងជិរំសាយធូ ។

វណ្ណៈ ចឹងរត់ទៅទាំងអស់គ្នា?

សារុនៈ អត់ទេ រត់ទៅខ្លះនៅនេះខ្លះ រត់ទៅភាគច្រើននៅនេះ ។

វណ្ណៈ ចឹងរត់ទៅសាយធូ?

សារុនៈ ចាស!ទៅសាយធូ ។

វណ្ណៈ រត់ខ្លះនៅខ្លះ?

សារុនៈ ចាស!រត់ខ្លះនៅខ្លះ រត់ទៅអីនោះច្រើនជាងនៅនេះ ។

វណ្ណៈ ចឹងអ្នកខ្លះរត់ទៅខាងយួន?

សារុនៈ ចាស ។

វណ្ណៈ ចឹងយួន៧៩មានចូលមកដល់នេះទេ?

សារុនៈ យួនចូលមកដល់នេះតើ នៅនេះឯងយួនមកនៅច្រើនមែនទែន ឆ្នាំប៉ុន្មានដែលយួនរំដោះទៅវិញ ។

វណ្ណៈ ឆ្នាំ៨០ជាងវៀតណាមដកទៅវិញ?

សារុនៈ ចាស!ត្រូវហើយ ។

វណ្ណៈ ចឹងកាលយួនចូលមកដល់ហ្នឹងអីចឹងទៅ ដល់ក្រោយមកទៀតនៅនេះមានបីភាគី?

សារុនៈ ចាស!មានបីភាគី ។

វណ្ណៈ មានប៉ារា មានខ្មែរក្រហម ។

សារុនៈ ចាស ។

វណ្ណៈ ចឹងប៉ារាមានពីរក្រុម?

សារុនៈ ចាស ។

វណ្ណៈ ចឹងកាល៧៩-៨០-៨២នៅហ្នឹងច្បាំងគ្នាអីហ្នឹងខ្ញុំចង់ឲ្យមីងរៀបរាប់ ការដែលរស់នៅជាមួយទ័ពអីចឹងដោយសារសង្គ្រាមព្រំដែនចឹងការរស់នៅយ៉ាងម៉េចដែរ?

សារុនៈ ការរស់នៅកាលសម័យសង្គ្រាមហ្នឹង មកវ៉ៃគ្នាអុកឡុកក្នុងភូមិក្នុងស្រុកហ្នឹងប៉ុន្មានលើកប៉ុន្មានសារ៤លើក ។

វណ្ណៈ បាទ ។

សារុនៈ ខ្មែរក្រហមវ៉ៃជាមួយយួន ប៉ារាក៏វ៉ៃជាមួយយួន យួនទៅវ៉ៃខ្មែរក្រហម យួនទៅវ៉ៃប៉ារាបីបួនសារនោះ ហើយយករបស់របរប្រជាជនអស់ពួកប៉ារាយកគោក្របីនាក់ស្រុកអស់២៨នឹម ។

វណ្ណៈ ចឹងខាងខ្មែរក្រហមមានដែលយកទេ?

សារុនៈ ខាងខ្មែរក្រហមមានដែលយកទេ យកតែប៉ារាហើយដោយទាំងខ្ញុំទៀតគោមួយនឹមដែរ ខ្ញុំទិញជាងមួយជំឡឹងយករបស់ខ្ញុំដែរ វាថាវ៉ៃខ្លាំងបានហើយវាយកវាថា ពុកខ្ញុំកុំអីក៏គាត់មិនទាន់ស្លាប់ គាត់ស្លាប់ដោយសាររបស់គាត់គោ ។

វណ្ណៈ ចឹងគោរបស់ប្រជាជនជាច្រើនក្បាល?

សារុនៈ ចាស ។

វណ្ណៈ ចឹងឲ្យតែចូលមកយកតែម្តង?

សារុនៈ ចូលមកតែវាវ៉ៃបានវាយក តែថាវាមិនបានវ៉ៃវាអត់យកទេ បើវាវ៉ៃជាមួយយួនណាស់វ៉ៃជាមួយយួនកោកកាកៗទៅបើវាស្លាប់ត្រដាបត្រដួលបើវាមិនយកគោក្របីប្រជាពលដឹកទៅវាយកទៅហើយវាមិនឲ្យមកវិញទេ វាយកទៅលក់ឲ្យថៃបាត់ ។

វណ្ណៈ ចឹងខ្មែរក្រហមវ៉ៃចូលមកមានដែលយកទេ?

សារុនៈ ខ្មែរក្រហមមិនដែលយកអីទេ ។

វណ្ណៈ ចឹងខាងប៉ារាខូចជាងខ្មែរក្រហម?

សារុនៈ ចាស!បើមួយសារទៀត អានេះនិយាយអាសារមុនណាស់វាមិនយកវាមិនបាត់អីហ្នឹង ហើយដល់មួយសារទៀតខ្មែរក្រហមវៃទៀត វៃអុចផ្ទះតែម្ដងត្រង់នេះ ។

វណ្ណៈ ចឹង?

សារុនៈ អាលើកក្រោយ ។

វណ្ណៈ បាទ ។

សារុនៈ លើកទី៣ ។

វណ្ណៈ បាទ ។

សារុនៈ ទី១ ខ្មែរក្រហម ទី២ប៉ារា ទី៣ខ្មែរក្រហមទៀតកាលហ្នឹងវាចូលមកអុចផ្ទះ ។

វណ្ណៈ ដុតផ្ទះទាំងអស់?

សារុនៈ ទេ ដុតផ្ទះទាំងអស់អីសុំលុយវារកលុយ ។

វណ្ណៈ ចឹងមានខ្មែរក្រហមខ្លះអាក្រក់ចឹង?

សារុនៈ ចាស!បើលោកពូមាន៥០០ឲ្យវា វាអត់អុចផ្ទះទេ បើទៅទានាងនោះឲ្យមួយពាន់វាមិនអុចទេផ្ទះ ចុះទៅរកឯណាបានសម័យនោះមានលុយមកពីណា ។

វណ្ណៈ ចឹងមានឆេះផ្ទះអ្នកស្រុកអ្នកភូមិច្រើនទេ?

សារុនៈ ឆេះច្រើនតើ ភូមិនេះឆេះអស់បួនខ្នងហើយភូមិខ្ញុំឯណោះឆេះអស់៦ខ្នងភូមិខាងកើត ។

វណ្ណៈ បាទ ។

សារុនៈ ចាស ។

វណ្ណៈ ដើរអុចផ្ទះប្រជាជន?

សារុនៈ ចាស ។

វណ្ណៈ ចឹងពេលធ្វើសង្គ្រាមជាមួយវៀតណាមចឹង ព្រោះនេះវាចឹងមើលឃើញ គេច្រើនបាញ់គ្នានៅពេលណា?

សារុនៈ ច្រើនបាញ់គ្នានៅម៉ោង៤ព្រឹក ។

វណ្ណៈ ខ្មែរក្រហមនិងវៀតណាមបាញ់គ្នា?

សារុនៈ ចាស!វៀតណាមខ្សែលីងនៅពេញភូមិ ងាប់ប្រជាពលរដ្ឋដែលតែតិចស្លាប់ងាប់និងត្រូវគ្រាប់ចុះដល់ពេលម៉ោង៤ឡើងក្រោកដាំបាយទៅស្រែ ដល់គ្រាំង១១មកទៅណាមានរួចងាប់ ។

វណ្ណៈ ចឹងមានប្រជាជនស្លាប់ច្រើនដែរ?

សារុនៈ ចាស ។

វណ្ណៈ ចឹងផ្ទះប្រជាជនមួយៗសុទ្ធតែមានត្រង់សេ?

សារុនៈ ចាស!សុទ្ធតែមានត្រង់សេគ្រប់ផ្ទះ ។

វណ្ណៈ ចឹងនៅពេលដែលវៀតណាមវ៉ៃបុកមកចឹង ប្រជាជនរត់ទៅតាមខ្មែរក្រហមដែលឬមួយមិនរត់ទេ?

សារុនៈ ភូមិនេះមិនមានរត់ទេ ក្រាបនៅត្រង់សេទាំងអស់គ្នា គេមិនមានរត់ទេ ។

វណ្ណៈ ចឹងទ័ពរត់ទៅបាត់ទៅ?

សារុនៈ ចាស!រត់ទៅបាត់ទៅ ។

វណ្ណៈ ចឹងនៅពេលវៀតណាមចូលមកមានសំឡុតប្រជាជនទេ?

សារុនៈ ចាស!មានសំឡុតខ្លះដែលតើ ។

វណ្ណៈ សំឡុតថាយ៉ាងម៉េច?

សារុនៈ សំឡុតថាឃើញប៉ុល ពតទេៗៗសួរថាចេះ ។

វណ្ណៈ បាទ ។

សារុនៈ ពួកខ្ញុំចេញមកឆ្លើយព្រៀតថាអត់មានទេ វាស្គាល់ដែលនោះ ។

វណ្ណៈ បាទ ។

សារុនៈ បើប៉ុល ពតវាបាញ់កាំភ្លើងទៅវាមិនធំក្លិន ចឹងវាដើរហិតមើលអាវ ។

វណ្ណៈ ចឹងដើរហិតអាវ?

សារុនៈ ចាស!ដើរហិតអាវប្រុសស្រីទាំងអស់គ្នា បើវាធំក្លិនវាចាប់បាត់កុហក់ម៉េចបានជាពួកវៀតណាមហ្នឹង ដែលកុហក់បាន ។

វណ្ណៈ ចឹងមានធំក្លិន?

សារុនៈ ចាសៗ!ធំក្លិនរំសេវ ចុះបាញ់គ្នាថ្មីៗវាមិនដឹងវាដើរហិត ដើរសំឡុតគ្រប់តែត្រង់សេហ្នឹងឯងមិនបានធ្វើបាបប្រជាពលរដ្ឋទេ រកតែពួកខ្មាំងហ្នឹងឯង ។

វណ្ណៈ ចឹងកាលហ្នឹងកងទ័ពខាងខ្មែរក្រហមកងទ័ពខាងប៉ុលពតមានដែលចាប់បានកងទ័ពវៀតណាមអីទេ?

សារុនៈ ចាប់បានខ្លះតើ ។

វណ្ណៈ ចាប់បានយកទៅណាមានដឹងទេ?

សារុន៖ វាយកទៅកន្លែងវា ។

វណ្ណៈ៖ យកទៅកន្លែងណា?

សារុន៖ យកទៅកន្លែងវាស្នាក់នៅក្តិបថ្មអីនោះ ។

វណ្ណៈ៖ ចឹងមីងជាប្រជាជនមានបានដឹងថា តាមខ្ញុំដឹងថាពេលខ្មែរក្រហមចាប់បានវៀតណាមចឹង យកទៅដាក់ក្នុងបន្ទាយចឹងទៅ?

សារុន៖ ចាស ។

វណ្ណៈ៖ ដូចថា១០០នាក់ចឹងដូរអង្ករជាមួយថៃ ថៃយកទៅទៀតតើរឿងនេះមីងមានបានដឹងទេ?

សារុន៖ ខ្ញុំមិនបានដឹងទេ ។

វណ្ណៈ៖ តែខ្ញុំបានសម្ភាសន៍ទ័ព ខាងទ័ពនិយាយចឹង?

សារុន៖ ចាស ។

វណ្ណៈ៖ អត់មានសម្ងាប់ទេ?

សារុន៖ ចាស ។

វណ្ណៈ៖ តែយកទៅដោះដូរអង្ករដូចថាយកទៅឲ្យថៃទៅ ថៃឲ្យអង្ករមកតែថៃបញ្ជូនទៅណាទៀតមិនបានដឹងទេ?

សារុន៖ ចាស ។

វណ្ណៈ៖ ហ្នឹងចឹង?

សារុន៖ ចាស ។

វណ្ណៈ៖ ចឹងនៅពេលខ្មែរក្រហមវៃចូលមកដេញយួនទៅវិញ តើខ្មែរក្រហមចូលមកមានទំនាក់ទំនងអ្វីជាមួយប្រជាជនទេ?

សារុន៖ មានទំនាក់ទំនងខ្លះដែរ វាថាបើឃើញយួនចូលមកឆាប់រាយការណ៍ មានអ្នកស្រុកណាហ៊ាន សុទ្ធតែថាមិនឃើញៗទៅ ចូលមកក៏ចូលទៅបើមិនបានប៉ះគ្នាទៅយើងក៏កុហកថែមទៅចុះខ្លាចនោះ បើវាបាញ់ប៉ុងបាំងៗក្នុងភូមិស្រុកនោះ ។

វណ្ណៈ៖ បាទ ។

សារុន៖ ម៉េចហ៊ានខ្ញុំក៏លាក់ទៅ កូនខ្ញុំក៏លាក់កូនឯងក៏លាក់ទៅណា ខ្លាចប្រាប់នេះម្តងនោះម្តងទៅខ្លាចវាធ្វើបាបយើង ។

វណ្ណៈ៖ បាទ ។

សារុន៖ ហើយកុហក់ទៅ ។

វណ្ណៈ ចឹងកាលហ្នឹងមានសិទ្ធសេរីភាពក្នុងការរកស៊ីអីទេ?

សារុនៈ មានរកស៊ីបានទេអាអូនអើយ ធ្វើស្រែចំការដូចជាយើងហក់លោតចឹង ខ្លាចចុះកូននៅផ្ទះ ម៉ែនៅព្រៃ បើកូនមាន៤ទៅ៥ចេះក៏បរទេះដឹកកូនទៅទាំងអស់ ។

វណ្ណៈ ចឹងគណៈស្រុកខាងរដ្ឋកម្ពុជាខាងសម្ដេចហ៊ុន សែនអីអត់មានចូលមកដល់នេះទេ?

សារុនៈ ចាស!កាលហ្នឹងគណៈស្រុកអីមិនហ៊ានមកទេ នៅតែត្រឹមស្វាយចេក ។

វណ្ណៈ ចឹងប្រជាជនមានសុខទុក្ខយ៉ាងម៉េចក៏មិនបានដឹងដែរ?

សារុនៈ មិនបានដឹងទេ ។

វណ្ណៈ រស់តាមដំណើរទៅ?

សារុនៈ ហើយបង្រួមភូមិទៅតើអាអូន បង្រួមភូមិទៅនៅថ្មពួកនោះ រួមពីភូមិខ្ញុំនេះទៅនៅថ្មពួក អស់រយៈ៨ឆ្នាំ ។

វណ្ណៈ បាទ!ចឹងអត់មាននៅនេះទេចឹង?

សារុនៈ អត់មាននៅនេះទេ តែដល់ត្រឡប់មកវិញចឹងឯងដែលវាអុកឡុកនោះ យួនមកនៅក៏មក អុកឡុកទៀតហ្នឹងឯង នេះខ្ញុំឲ្យកត់មុនថាបាញ់គ្នាវៃគ្នានេះណា ។

វណ្ណៈ បាទ ។

សារុនៈ ក្រោយនេះឯង កាលមុនដំបូងគេមិនព្រមទៅ ។

វណ្ណៈ បាទ ។

សារុនៈ ដល់នៅទៅវៃគ្នាប៉ុន្មានលើកប៉ុន្មានសារវេទនាណាស់ស្រុកខ្ញុំភូមិខ្ញុំនោះកម្មមានកូនបួនប្រាំ នាក់មិនហ៊ានឲ្យកូនទៅណាឆ្ងាយពីត្រង់សេទេ ឲ្យកូនហូបបាយហើយឲ្យកូនដេកលេងក្នុង ត្រង់សេទៅ វាជួនថ្ងៃជួនយប់ ។

វណ្ណៈ ចឹងក្មេងៗមានបានរៀនបានសូត្រអីទេ?

សារុនៈ រៀនពេលវៀតណាមទៅផុតហើយបានរៀនតើ ពួកកូនខ្ញុំរៀនទាំងអស់គ្នា ។

វណ្ណៈ ចឹងទើបរៀនក្រោយទេ?

សារុនៈ ចាស ។

វណ្ណៈ កាលឆ្នាំ៧៩-៨០-៨១-៨២ហ្នឹងក្មេងៗអត់មានបានរៀនទេ?

សារុនៈ ចាស!បានរៀនខ្លះៗ អាបងៗបានរៀនខ្លះហ្នឹងឯង ។

វណ្ណៈ ចឹងរៀនខ្លះអត់ខ្លះទៅ?

សារុនៈ ចាស ។

វណ្ណៈ៖ ព្រោះអីមានសង្គ្រាមរហូត?

សារុន៖ ចាស!បើមីបងគេបន្ទុសខ្ញុំថា៤០នាក់រស់តែមួយនោះ អត់មានចេះអក្សរទេ ។

វណ្ណៈ៖ បាទ ។

សារុន៖ ចុះបើគ្នាលែងតែរត់នោះ ម៉េចបានចេះអក្សររៀនធំហើយម៉េចបានចេះធំហើយ ។

វណ្ណៈ៖ បាទ ។

សារុន៖ ចាស!កូនខ្ញុំឡើង៧នាក់នោះ ។

វណ្ណៈ៖ បាទ ។

សារុន៖ ប្រុសពីរស្រី៥ ។

វណ្ណៈ៖ ចឹងនៅនេះមានប៉ុភមានខ្មែរក្រហមផង?

សារុន៖ ចាស!ហើយមានវៀតណាមផង ។

វណ្ណៈ៖ ហើយមករស់នៅឡូកឡំជាមួយគ្នាទៅ?

សារុន៖ ចាស ។

វណ្ណៈ៖ ដេញទៅដេញមកទៅ?

សារុន៖ ចាស!វេទនាណាស់អូនអើយ ។

វណ្ណៈ៖ ចឹងនៅពេលដែលកងទ័ពវៀតណាមដកផុតទៅនៅសល់តែទាហានរដ្ឋាភិបាលហ៊ុន សែន ហ្នឹងវ៉ៃជាមួយខ្មែរក្រហមវ៉ៃជាមួយប៉ុភទៀតហ្នឹង កាលហ្នឹងសង្គ្រាមខ្លាំងឬមួយខ្សោយចុះខ្សោយ?

សារុន៖ ពេលនោះចុះខ្សោយហើយ ។

វណ្ណៈ៖ ចឹងលែងសូវមានហើយ?

សារុន៖ លែងសូវមានហើយ ។

វណ្ណៈ៖ វ៉ៃតែមួយប្រ៉ាវៗ?

សារុន៖ ចាស!វ៉ៃតែមួយប្រ៉ាវពេលនោះភូមិខ្ញុំស្ងាត់តើ មានតែនៅថ្មពួកនោះ ។

វណ្ណៈ៖ បាទ ។

សារុន៖ មានតែទៅខាងថ្មពួកនោះខាងនេះស្ងាត់ហើយ អត់មានអីទេព្រោះវៀតណាមដកហើយ ។

វណ្ណៈ៖ បាទ ។

សារុន៖ បើខ្មែរក្រហមនិងប៉ុភប៉ះគ្នាម្ដងៗប៉ះតែតាមព្រៃបាញ់តែព្រៃ ។

វណ្ណៈ៖ ចឹងខ្មែរក្រហមនិងប៉ុភមានបាញ់គ្នាដែរ?

សារុនៈ បាញ់ ។

វណ្ណៈ ចឹងនៅហ្នឹងកាលជំនាន់និរតីចូលមកមានស្គាល់យាយថែមអីទេ?

សារុនៈ មិនមានយាយថែមនៅនេះទេ អត់មានអត់ស្គាល់ទេ មិនមានទេមិនបានមកដល់នេះទេ យាយថែមល្បីតែនោះណាស់ ស្អី...?

វណ្ណៈ ព្រះនេត្រព្រះ?

សារុនៈ ចាស!ព្រះនេត្រព្រះអីនោះឯង ពួខាងនោះឯង ។

វណ្ណៈ តែតំបន់៥ហ្នឹងគាត់គ្រប់គ្រងដែលតើ?

សារុនៈ គាត់គ្រប់គ្រងតែមិនដែលឃើញគាត់មក ។

វណ្ណៈ ចឹងមីងថាលើកទំនប់អី?

សារុនៈ លើកទំនប់អាងជើងគ្រោះ ។

វណ្ណៈ ចឹងនៅអាងជើងគ្រោះគាត់មានមកដែរ?

សារុនៈ អត់ឃើញ ។

វណ្ណៈ ចឹងលើកទំនប់ហ្នឹងមានស្លាប់មនុស្សច្រើនដែរ?

សារុនៈ ច្រើន! ស្លាប់ច្រើន ។

វណ្ណៈ យ៉ាងម៉េចបានស្លាប់?

សារុនៈ ម៉េចបានស្លាប់បើវាវៃចោលនោះ ។

វណ្ណៈ ចឹងស្លាប់ដោយសារវៃចោល?

សារុនៈ ស្លាប់ដោយសារវៃចោល ។

វណ្ណៈ ចឹងប្រជាជនទៅលើកទំបន់ហ្នឹងទាំងអស់គ្នាទាំងយុវជនទាំងនារីទាំងកសិករឬយ៉ាងម៉េច?

សារុនៈ ពួកដែលជម្លៀសមកពីភ្នំពេញនោះទៅច្រើន នារីយុវជនចាស់ក្មេងអីទៅទាំងអស់ហើយ ភូមិខ្ញុំនេះមានតែនារីយុវជនហ្នឹងឯង ។

វណ្ណៈ លើកទំនប់អីគេ?

សារុនៈ លើកទំនប់អាងជើងគ្រោះ ។

វណ្ណៈ មានស្លាប់ប្រជាជនច្រើន?

សារុនៈ ចាស ៗ !ស្លាប់ច្រើន ។

វណ្ណៈ ចឹងស្លាប់ដោយវៃចោលហ្នឹងអត់អាហារ?

សារុនៈ ចាស ។

វណ្ណៈ	ចឹងមីងជំនាន់ខ្មែរក្រហមដែលមីងធ្លាប់ឆ្លងកាត់បីឆ្នាំហ្នឹងមីងមានបាត់បង់សាច់ញ្ញាតបងប្អូនអីខ្លះទេ?

សារុន៖	មានក្មួយមួយគ្រួសារ ក្មួយខ្ញុំបង្កើតគេយកទៅវ៉ៃចោល ។

វណ្ណៈ	គេយកទៅវ៉ៃចោលនៅកន្លែងណា?

សារុន៖	នៅកន្លែងដីកន្លែងប្រលាក់ដែកកេះដែលអូនឯងតេទៅមិញហ្នឹងនោះ ។

វណ្ណៈ	បាទ ។

សារុន៖	នៅកន្លែងនោះឯងវ៉ៃចោលអស់មួយគ្រួសារ ក្មួយខ្ញុំមានប្ដីកូនពីរនាក់ទាំងអស់ងាប់អស់បួននាក់ហើយតាំងកូនទាំងម៉ែនិងប្ដី ។

វណ្ណៈ	បាទ ។

សារុន៖	មានតែម្នាក់ប៉ុណ្ណោះឯងក្រុមគ្រួសារខ្ញុំ ។

វណ្ណៈ	ចឹងមកដល់ឥឡូវមានអ្នកដែលគេធ្លាប់រស់នៅជំនាន់ខ្មែរក្រហមអ្នកភ្នំពេញអ្នក១៧មេសាមកដល់ឥឡូវមានអ្នកខ្លះមកលេងអ្នកភូមិខ្លះដែរទេប្អូនត់សោះ?

សារុន៖	ចាស!មានមកតើ ។

វណ្ណៈ	មកលេង?

សារុន៖	ចាស!មកលេងខ្លះតើគេអ្នកស្គាល់គ្នាគេបានរស់នៅជាមួយគ្នាខ្លះទៅ គេបានមកជួបជុំគ្នាខ្លះតើ ។

វណ្ណៈ	ចឹងមានមកលេងជាមួយអ្នកស្រុកអ្នកភូមិហ្នឹង?

សារុន៖	ចាស ។

វណ្ណៈ	ដូចថាអ្នកស្រុកអ្នកភូមិធ្លាប់រាប់អានចឹង?

សារុន៖	ចាស ។

វណ្ណៈ	ធ្លាប់អាណិតស្រឡាញ់អីចឹង?

សារុន៖	ចាស!មានមកដែរ ។

វណ្ណៈ	ដល់ពេលចឹងគេបានរួចជីវិតទៅគេរកស៊ីមានបានគេមកលេង?

សារុន៖	ចាស!គេមកលេងនោះភូមិខ្ញុំគេមកលេងជិតបន្ទាយឆ្នាំនេះឯង ។

វណ្ណៈ	បាទ!ធម្មតាមនុស្សទោះបីធ្វើខ្មែរក្រហមមិនធ្វើខ្មែរក្រហមក៏ដោយក៏មានមនុស្សល្អមនុស្សអាក្រក់ចឹងដែរ?

សារុន៖	ចាស ។

វណ្ណៈ	ទោះអ្នក១៧មេសា ទោះបីអ្នកមូលដ្ឋានចាស់មានចិត្តអាណិតនឹកឃើញកូនគេកូនឯងចឹង ដែរ?

សារុន៖	ចាស ។

វណ្ណៈ	ចឹងមីងកន្លងមកមានដែលបានស្ដាប់វិទ្យុទាក់ទងនិងការកាត់ទោសមេដឹកនាំខ្មែរក្រហមអីទេ ?

សារុន៖	ខ្ញុំអត់មានរ៉ាត់យោជង អត់មានបានអីស្ដាប់និងគេ ។

វណ្ណៈ	ចឹងមីងរាល់ថ្ងៃហ្នឹងមីងមានដឹងថាមានការកាត់ទោសអីទេ មានដឹងតាមសារពត៌មានឬបាន ដឹងតាមអីខ្លះដែរ?

សារុន៖	អត់មានដឹងទេ បើអត់មានអីស្ដាប់និងគេបានអីនិងដឹង មិនដែលឮនណានិយាយថាអី ។

វណ្ណៈ	ចឹងចំពោះតុលាការដែលបង្កើតមកដល់សព្វថ្ងៃនេះ កាត់មេដឹកនាំខ្មែរក្រហមដូចជាតា ប៉ុល ពតគាត់ស្លាប់ហើយ ។

សារុន៖	ចាស ។

វណ្ណៈ	នៅតា អៀង សារី តា នួន ជា ប្រពន្ធអៀង សារី តា ខៀវ សំផន តា នួន ជា ឌុចអីហ្នឹង?

សារុន៖	ចាស ។

វណ្ណៈ	សព្វថ្ងៃគេឃុំខ្លួនគាត់នៅសាលាក្ដីខ្មែរក្រហម នៅទីក្រុងភ្នំពេញ ។

សារុន៖	ចាស ។

វណ្ណៈ	គេកាត់ទោសគាត់ពីបទធ្វើឲ្យមនុស្សស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិតេយ្យហ្នឹង?

សារុន៖	ចាស ។

វណ្ណៈ	ចឹងមីងគិតថាចាប់តែមេដឹកនាំជំនាន់ខ្មែរក្រហមឲ្យមានទោសហ្នឹង មីងគិតថាជាការត្រឹម ត្រូវឬមិនត្រឹមត្រូវទេ?

សារុន៖	មិនត្រូវទេ ។

វណ្ណៈ	យ៉ាងម៉េចបានមិនត្រឹមត្រូវ?

សារុន៖	ម៉េចមិនត្រឹមត្រូវបើគាត់សម្លាប់គេអស់ច្រើននោះ ។

វណ្ណៈ	ចឹងមីងមិនទាន់យល់សំនួរទេ ដូចថាចាប់មេដឹកនាំខ្មែរក្រហមទាំងអស់ហ្នឹងយកទៅកាត់ ទោសមីងគិតថាកាត់ទោសត្រឹត្រូវឬមិនត្រឹមត្រូវ?

សារុន៖	ត្រឹមត្រូវហើយចុះ ត្រឹមត្រូវហើយខ្ញុំស្ដាប់មិនបានចេះតែឆ្លើយ ។

វណ្ណៈ៖ ចឹងមានមូលហេតុអីបានមីងថាត្រឹមត្រូវ?

សារុនៈ មូលហេតុដោយគាត់បានធ្វើបាបប្រជាពលរដ្ឋច្រើនបែបច្រើនយ៉ាងពេកសម្លាប់ចោលអស់ច្រើននោះ។

វណ្ណៈ៖ បាទ។

សារុនៈ ហើយធ្វើបាបសព្វបែបយ៉ាង។

វណ្ណៈ៖ ចឹងមីងគិតថាកាត់ទោសទៅមានផលប្រយោជន៍អីខ្លះ មានសារសំខាន់ទេពេលមានតុលាការកាត់ទោសចឹង?

សារុនៈ មានសារសំខាន់បងប្អូនប្រជាពលរដ្ឋបាត់បង់ជីវិតទៅ ឲ្យគ្នាមានសេរីភាពដែលគ្នាស្លាប់ទៅហើយ។

វណ្ណៈ៖ ចឹងខ្ញុំអរគុណមីងច្រើនហើយ។

សារុនៈ ចាសៗ។

**ចប់**